**មាត្រា ២ :** ប្រគល់ជូនទៅក្រសួងការពារជាតិវិញ នូវ ឧបករ និង បុគ្គលិកយោធាទាំងអស់ដែលបំរើការងារក្នុងខុទ្ទកាល័យនេះ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិសហរដ្ឋ មន្ត្រីក្រសួងមហាផ្ទៃ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ បណ្តាក្រសួងដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

***

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៩*

## អនុក្រឹត្យលេខ ៤៣ អនក្រ
## ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅរាជធានីភ្នំពេញ
## និង ខេត្ត ក្រុង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ :** ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសាធារណៈ ភាពស្ងប់ស្ងាត់អនាម័យ និង ភាពនាំអោយមានសុខភាពល្អ នៅរាជធានីភ្នំពេញ និង ខេត្ត ក្រុង ជាកាតព្វកិច្ចរបស់ជនគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជនគ្រប់រូបត្រូវតែគោរពអោយបានហ្មត់ចត់តាមបទបញ្ញានានា របស់អាជ្ញាធររាជធានីភ្នំពេញ និង ខេត្ត ក្រុង ដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសាធារណៈ ភាពស្អាតអនាម័យ និង ភាពនាំអោយមានសុខភាពល្អទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ :** ការប្រព្រឹត្តល្មើសនឹងបទបញ្ញានៃសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសាធារណៈភាពស្អាតអនាម័យ និង ភាពនាំអោយមានសុខភាពល្អ ដែលមានចែងក្នុងអនុក្រឹត្យនេះ គឺជាបទលហុ ។

បទលហុជាបទល្មើសនឹងបទបញ្ញារបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការរៀបចំ ការរស់នៅ ជាទូទៅ នៅក្នុងសង្គម នៃ ព្រះរាជាណាចក្រកម្ពុជាហើយអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិដាក់ទណ្ឌកម្មដូចតទៅ ÷

- ការព្រមាន
- ការពិន័យជាប្រាក់
- ការសារុះសារួលពីសំណងនៃការខូចខាត

**មាត្រា ៣ :** នីតិវិធីនៃការព្រមាន ការពិន័យជាប្រាក់ ២.០០០រ ដល់ ៥០.០០០រ និងការសារុះសារួលពីសំណងនៃការខូចខាត ចំពោះបទល្មើសនឹង មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយដីការបស់អាជ្ញាធររាជធានីភ្នំពេញ និង ខេត្ត ក្រុង ដោយមានការយល់ព្រមពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ប្រាក់ពិន័យនេះត្រូវបង់ចូលថវិកាជាតិក្រោយពីកាត់ ៤០ ភាគរយសំរាប់ផ្តល់ជារង្វាន់ដល់ភ្នាក់ងារ ឬអង្គភាពនានា ដែលមានសមត្ថកិច្ច ។

**មាត្រា ៤ :** ជនណាចោល ឬ ចាក់សំរាមក្រៅពីកន្លែងចាក់សំរាម ឬ ធុងសំរាមដែលកំណត់ ដោយ អាជ្ញាធរមានសមត្ថកិច្ចត្រូវពិន័យជាប្រាក់ ២.០០០រ ។ ក្នុងករណីមិនរាងចាលត្រូវពិន័យទ្វេរមួយជាពីរ ឬជាបី ឬជាបួនតាមការល្មើសជាក់ស្តែង ។

**មាត្រា ៥ :** ជនណាចោលខ្មោចសត្វតាមផ្លូវ ឬ ទីធ្លាសាធារណៈត្រូវពិន័យជាប្រាក់ ៥.០០០រ ។ ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ ១០.០០០រ ។

**មាត្រា ៦ :** ជនណាចាក់សំរាម កាកសំណល់សាងសង់ សាកសពសត្វក្នុងអណ្តូង លូ ក្នុងប្រឡាយបង្ហូរទឹក ត្រូវពិន័យជាប្រាក់១០.០០០៛ ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ ២០.០០០៛ ។

**មាត្រា ៧ :** ជនណារៀបចំពិធីបុណ្យផ្សេងៗនៅលើទីសាធារណៈ ហើយមិនបោសសំអាតអោយស្អាតដូចដើមត្រូវពិន័យជាប្រាក់ ៥០.០០០៛ ។

**មាត្រា ៨ :** គ្រប់អាគារ សណ្ឋាគារ ភូមិគ្រឹះ ស្ថាប័ន ក្រសួងទាំងអស់ត្រូវមានធុងសំរាម។ ក្នុងករណីគ្មានធុងសំរាមហើយបោសសំអាតគរស្មោយរល្វយ ធុំក្លិនស្អុយប៉ះពាល់ដល់សុខភាពអ្នកជិតខាង ត្រូវហៅមកព្រមានជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ២០.០០០៛ ។

**មាត្រា ៩ :** ជនណាសាងសង់បង្គន់ខ្វះអនាម័យ បណ្តាលអោយធុំក្លិនស្អុយប៉ះពាល់ដល់សុខភាពអ្នកជិតខាង ត្រូវហៅមក ព្រមានជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ២០.០០០៛ ។

**មាត្រា១០ :** ជនណាហាលខោអាវនៅពីមុខផ្ទះនាំអោយខូចសោភ័ណ្ឌភាពរាជធានីភ្នំពេញ ខេត្ត ក្រុង ត្រូវព្រមានជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ១០.០០០៛ ។

**មាត្រា១១ :** ជនណាលែងសត្វចតុបាទអោយដើរពាសវាលពាសកាលក្នុងទីប្រជុំជននានា នៅលើទីសាធារណៈ ត្រូវចាប់សត្វទាំងនោះ និង ហៅម្ចាស់មកព្រមានជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ៣.០០០៛ ក្នុងសត្វចតុបាទមួយក្បាល ។

**មាត្រា១២ :** ជនណាដាក់តាំងទំនិញលក់គ្មានសណ្តាប់ធ្នាប់នៅលើទីសាធារណៈ ដែលត្រូវហាមឃាត់ត្រូវហៅមកព្រមានជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ១០.០០០៛ ។

**មាត្រា១៣ :** ជនណារែកទូល រុញរទេះ លក់ដូរក្នុងទីសាធារណៈដែលត្រូវហាមឃាត់ត្រូវហៅមកធ្វើការ ព្រមានជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ២.០០០៛ ។

**មាត្រា១៤ :** ជនណាសាងសង់សំណង់គ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ត្រូវហៅមកព្រមានចុះកិច្ចសន្យារុះរើដោយខ្លួនឯងជាបឋម ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ ៥០.០០០៛ និង បង្ខំអោយរុះរើតាមកិច្ចសន្យា។

**មាត្រា១៥ :** ជនណាជីកផ្លូវថ្នល់សាធារណៈ គ្មានការអនុញ្ញាតច្បាប់ត្រឹមត្រូវ ត្រូវពិន័យជាប្រាក់ ៥០.០០០៛ និងសងសោហ៊ុយជួសជុលការខូចខាតដែលខ្លួនបានធ្វើ ។

**មាត្រា ១៦:** ជនណាបង្កសម្លេងកងរំពង ឬឈ្លោះប្រកែកគ្នាធ្វើអោយប៉ះពាល់ដល់ភាពស្ងប់ស្ងាត់ និងសណ្តាប់ធ្នាប់សាធារណៈដោយគ្មានការអនុញ្ញាតត្រូវពិន័យជាប្រាក់ ៥.០០០៛ ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ទ្វេរមួយជាពីរ ។

**មាត្រា១៧ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១៨ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៤៤ អនក្រ
## ស្តីពីទិដ្ឋាការ បញ្ជីការឱសថ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**សំរេច**

**មាត្រា ១ :** ឱសថគ្រប់ប្រភេទដែលផលិតក្នុងប្រទេសអាចតាំងលក់បាន លុះត្រាតែមានចុះលេខទិដ្ឋាការយល់ព្រមពីក្រសួងសុខាភិបាល ។

**មាត្រា ២ :** ឱសថគ្រប់ប្រភេទដែលនាំចូលពីបរទេស អាចតាំងលក់បានលុះត្រាតែមានចុះលេខ បញ្ជីការយល់ព្រមពីក្រសួងសុខាភិបាល ។